**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~~x~~~~

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
~~~~x~~~~

# របាយការណ៍ការងារ

# ប្រចាំឆ្នាំ ២០១០

# និង

# ទិសដៅការងារឆ្នាំ ២០១២

~~*~~

ដោយមានការខិតខំព្យាយាមក្នុងការងាររបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ទាំងស្មារតី និងសំភារៈ រួមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នជាតិ អន្តរជាតិនានាផងនោះ ធ្វើឲ្យដំណើរការកែលម្អ និងលើកកំពស់ការអនុវត្តន៍វិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជា កាន់តែមានភាពរឹងមាំ និងល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងការរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ សកម្មភាពជាក់ស្តែងក្នុងឆ្នាំ ២០១១ នេះ នាយកដ្ឋានទទួលបានលទ្ធផលការងារដូចខាងក្រោម:

## I-លទ្ធផលការងារដែលទទួលបាន

### ក-ការងាររៀបចំច្បាប់ និងបទបញ្ញត្តិនានា

#### ក១-ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម

-រៀបចំសេចក្តីព្រាងប្រកាស ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានចុះហត្ថលេខានៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ ។

-រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពី ការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់ កម្មសិទ្ធិបញ្ញា និង អនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ ។

-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យស្តីពី «វិធានការណ៍តាមព្រំដែន» ដែលចែងលំអិត អំពីនីតិវិធី អនុវត្តការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាតឲ្យម្ចាស់សិទ្ធិ ដាក់ពាក្យទៅអជ្ញាធរគយ ឬ កាំកុងត្រូលជាមុន ដើម្បីផ្អាកការនាំចូលទំនិញដែលសង្ស័យ ឬមានការរំលោភបំពានកម្មសិទ្ធិបញ្ញា។

-បន្តសិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យស្តីពី «ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ( Sub- Decree on Enforcement of IPRs)» ក្នុងគោលបំណងចាត់វិធានការណ៍ឲ្យមានប្រសិទ្ធិភាពជាងមុន ដោយកិច្ចសហការរវាងអង្គភាពពាក់ព័ន្ធដូចជា តុលាការ ព្រះរាជអាជ្ញា ប៉ូលីសសេដ្ឋកិច្ចនិងនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិបញ្ញានានា។

## ក២-ក្នុងក្របខ័ណ្ឌអន្តរក្រសួង

-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យស្តីពី «ការត្រួតពិនិត្យ ការផលិត ការនាំចូលថាស (CDs)» ក្នុងគោលបំណងការពារកុំឲ្យកម្ពុជា ក្លាយជាប្រទេសផលិត CDs ក្លែងក្លាយក្នុងបរិមាណច្រើន ហើយនាំចេញទៅប្រទេសក្រៅ។

-ជំរុញ និង សហការជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្នុងការរៀបចំព្រាងអនុក្រឹត្យស្តីពី «ការបង្កើត អង្គភាពគ្រប់គ្រងសិទ្ធិរួម» ក្នុងគោលបំណងប្រមូល លាភការដល់អ្នកសំដែង និងអ្នកផលិតហ្វូណូក្រាម។

-បន្តជំរុញ និងសហការជាមួយក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «សៀគ្វីរួមបញ្ចូលគ្នា» ឲ្យបានសមស្របតាមស្តង់ដាអន្តរជាតិ។

-សហការពិនិត្យច្បាប់ ប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីអាចទាញយកអត្ថប្រយោជន៍ ពីឋានៈប្រទេសក្រីក្រ (LDCs) នៃកម្ពុជាក្នុងការធ្វើវិសោធនកម្មច្បាប់ខាងលើ ឬរៀបចំច្បាប់បន្ថែមថ្មីស្តីពី «ការផ្តល់អាជ្ញាប័ណ្ណបញ្ញាសំរាប់សុខភាពសាធារណៈ» ដែលជាអត្ថប្រយោជន៍ ក្នុងការផលិតឱសថទូទៅ «Generidrugs» នៅកម្ពុជាក៏ដូចជាការនាំចេញ-នាំចូល នូវប្រភេទឱសថខាងលើ។

-សហការពិនិត្យផលចំនេញ និង ប៉ះពាល់ក្នុងការចូលពិធិសាទីក្រុងម៉ាដ្រីត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ និងសន្ធិសញ្ញាស្តីពីម៉ាក។

## ខ-ការងារផ្សព្វផ្សាយ និងសហប្រតិបត្តិការអន្តរជាតិ

### ខ១-ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាល

#### ខ១-១-រៀបចំសិក្ខាសាលាបំប៉នជំនាញកម្មសិទ្ធិបញ្ញាក្នុងប្រទេស

-រៀបចំសិក្ខាសាលារបាយការណ៍ស្តីពី Development Dimension of IP in Cambodia: Copyright, Growth, Education and Culture, Needs Assessment Diagnostic ដោយសហការជាមួយ UNCTAD/ICTSD នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ Hotel Intercontinental ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ និងរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលដោយក្រសួងពាណិជ្ជកម្ម និងជំនាញការ UNCTAD/ICTSD ។

-រៀបចំសិក្ខាសាលាស្តីពី Vienna Code and Nice Classifications នៅថ្ងៃទី ១៧-១៨ ខែ មករា ឆ្នាំ ២០១១ ដែលបង្រៀនដោយជំនាញការមកពីអង្គការ WIPO និងមានការចូលរួមពីមន្ត្រីនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម បុគ្គលិករបស់ភ្នាក់ងារកម្មសិទ្ធិបញ្ញា និងនិស្សិតមួយចំនួន។

-រៀបចំសិក្ខាសាលាជាតិ ស្តីពីការគ្រប់គ្រងទ្រព្យកម្មសិទ្ធិបញ្ញាដោយសហគ្រាសធុនតូច និងមធ្យម (National workshop on IP Asset Management by SMEs) នៅថ្ងៃទី ១១-១២ ខែ មិថុនា ឆ្នាំ ២០១១ ដែលសហការរៀបចំដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងអង្គការ WIPO។

-រៀបចំសិក្ខាសាលាជាតិ ស្តីពីការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា (Enforcement of Intellectual Property Rights) ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១ ដោយមានការចូលរួមពីជំនាញការអន្តរជាតិ សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា សកលវិទ្យាល័យ សហគ្រាស និងភ្នាក់ងារកម្មសិទ្ធិបញ្ញា។

-រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដល់មន្ត្រីនាយកដ្ឋានកម្ម សិទ្ធិបញ្ញាទាំងអស់ ដើម្បីឲ្យពួកគេកាន់តែមានមូលដ្ឋានចំណេះដឹងខ្ពស់ និងស្វែងយល់អំពី ទស្សនទាន នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងការលើកស្ទួយ និងការការពារទំនិញសម្គាល់ភូមិសាស្ត្រ ។

#### ខ១-២-ការងារប្រជុំ និងពិភាក្សា

-រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី សេចក្តីព្រាងរបាយការណ៍របស់សន្និសិទសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍ (UNCTAD) និងមជ្ឈមណ្ឌលអន្តរជាតិស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍ចីរភាព (ICTSD) ស្តីពីទំហំអភិវឌ្ឍនៃកម្មសិទ្ធិបញ្ញានៅកម្ពុជា៖ សិទ្ធិអ្នកនិពន្ធ ការរីកចម្រើន ការអប់រំ និងវប្បធម៌ (Development Dimension of IP in Cambodia: Copyright, Growth, Education and Culture) និងការវាយតម្លៃតម្រូវការជំនួយបច្ចេកទេសផ្នែកកម្មសិទ្ធិបញ្ញា (Needs Assessment Diagnostic) នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១១ ។

- -រៀបចំកិច្ចប្រជុំ ស្តីពីការប្រមូលព័ត៌មានកម្មសិទ្ធិបញ្ញាបច្ចុប្បន្ន និងការចងក្រងកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញា នៅថ្ងៃទី ១៥ និង ១៦ ខែ សីហា ឆ្នាំ ២០១១ ដោយមានការចូលរួមពីជំនាញការជាតិ និង អន្តរជាតិសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាសកលវិទ្យាល័យ និងភាគីពាក់ព័ន្ធនានា ។

-រៀបចំកិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា (NCIPR) ដើម្បីពិនិត្យ លើសេចក្តីព្រាងច្បាប់ ស្តីពីអាជ្ញាប័ណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

-រៀបចំទទួល និងបង្ហាញឱកាសទីផ្សារវិនិយោគអាជីវកម្ម និងការការពារកម្មសិទ្ធិបញ្ញានៅកម្ពុជា នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។ រៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពីលទ្ធភាពនៃការធ្វើសមាហរណកម្ម ការគ្រប់ គ្រង និងធនធានរដ្ឋបាលកម្មសិទ្ធិបញ្ញានៅកម្ពុជា នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១។

## ខ១-៣-ការចោះបញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលានៅក្រៅប្រទេស

| អង្គភាព | ចំនួន |
|---|---|
| នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម | ៥០ |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១៦ |
| សកលវិទ្យាល័យនានា | ៤ |
| តុលាការ | ៤ |
| កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម | ៤ |
| សមាគមឧស្សាហកម្មខ្នាតតូចនិងមធ្យម | ៣ |
| ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ៣ |
| នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ ក្រសួងពាណិជ្ជកម្ម | ២ |
| ក្រសួងយុត្តិធម៌ | ២ |
| ក្រសួងមហាផ្ទៃ | ២ |
| អគ្គនាយកនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | ១ |
| នាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | ១ |
| អគ្គនាយក នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | ១ |
| សភាពាណិជ្ជកម្មកម្ពុជា | ១ |

## ខ-ការចោះសហប្រតិបត្តិការអន្តរជាតិ

-នាយកដ្ឋានបានទទួលគណៈប្រតិភូ របស់សាធារណៈរដ្ឋប្រជាមានិតចិន (SIPO) មកធ្វើដំណើរទស្សនៈកិច្ចក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងពង្រឹង កិច្ចសហប្រតិបត្តិការផ្នែកកម្មសិទ្ធិបញ្ញា រវាង

ប្រទេសទាំងពីរ និងបានរៀបចំកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ ក្រោមអធិបតីយភាពរបស់ **ឯកឧត្តម ខិត ឌីណា** ព្រមទាំងបាន ចុះហត្ថលេខាលើអនុសារណៈ នៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងការិយាល័យ SIPO នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១១។

- -នាយកដ្ឋានបានរៀបចំ និងទទួលបេសកកម្មការងារនៅកម្ពុជា របស់ជំនាញការអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងជំនាញការអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ស្តីពី Quality Improvement of Tokyo Training Course Mission ពីថ្ងៃទី ១៩ ដល់ ២០ ខែ កញ្ញា ឆ្នាំ ២០១១។

-នាយកដ្ឋានបានរៀបចំ និងទទួលបេសកកម្មការងារនៅកម្ពុជា របស់ជំនាញការអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពី IPAS administrator training ចាប់ពីថ្ងៃទី ១៦ ដល់ ២៩ ខែ តុលា ឆ្នាំ ២០១១។

-នាយកដ្ឋានបានសហការជាមួយគំរោង The ASEAN Project on the Protection of Intellectual Property Rights (**ECAP III**) បានធ្វើការបកប្រែលើវិញ្ញាបនប័ត្រការចុះបញ្ជីរបស់ស្តុរត្នោតកំពង់ស្ពឺ និងម្រេចកំពត ពីភាសាខ្មែរ ទៅជាភាសាអង់គ្លេស ដើម្បីបង្ហោះលើគេហទំព័ររបស់ **ECAP III**។

## គ-កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

### គ១-ធនធានមនុស្ស

នាយកដ្ឋានមានមន្ត្រីរាជការសរុបចំនួន ៦១នាក់ ក្នុងនោះមន្ត្រីរាជការថ្នាក់នាយកដ្ឋានមានចំនួន ០៥នាក់ និងថ្នាក់ការិយាល័យមានចំនួន ២៤នាក់។

### គ២-ការងារថវិកា

ក្នុងឆ្នាំ២០១១នេះ នាយកដ្ឋានបានរកចំណូលថវិកាបង់ជូន នាយកដ្ឋានរដ្ឋបាលរបស់ក្រសួងសរុបចំនួន **១.០៤៩.០០០.០០០,០០៛** (មួយពាន់សែសិបបួនលានរៀល) ដែលក្នុងនោះរួមមាន ៖

| | | |
|---|---|---|
| -កំរៃនៃការដាក់ពាក្យសុំចុះបញ្ជីម៉ាក | : | ៨៩.១៨០.០០០,០០៛ |
| -កំរៃនៃការចុះបញ្ជីម៉ាក | : | ៦៥៨.៦២០.០០០,០០៛ |
| -កំរៃនៃការបញ្ជាក់ ការប្រើប្រាស់បញ្ជីម៉ាក | : | ៦៥.៦៨០.០០០,០០៛ |
| -កំរៃនៃការផ្ទេរកម្មសិទ្ធិម៉ាក | : | ១៧.៧២០.០០០,០០៛ |
| -កំរៃនៃការប្តូរឈ្មោះម្ចាស់ម៉ាក | : | ១៨.៦៨០.០០០,០០៛ |
| -កំរៃនៃការកែតម្រូវនានា | : | ១.៦៨០.០០០,០០៛ |
| -កំរៃនៃការក្នុងការប្តូរអាស័យដ្ឋាន | : | ១៣.៤៨០.០០០,០០៛ |
| -កំរៃក្នុងការលុបម៉ាកចេញពីបញ្ជី | : | ៣.៤០០.០០០,០០៛ |
| -កំរៃនៃការចុះបញ្ជីសារឡើងវិញ | : | ១៧៥.៦០០.០០០,០០៛ |
| **សរុបៈ** | | **១.០៤៩.០០០.០០០,០០៛** |

## តារាងប្រៀបធៀបចំណូលឆ្នាំ២០១០ នឹងឆ្នាំ២០១១

| លរ | បរិយាយមុខចំណូល | | ការប្រៀបធៀបចំណូល | | | | |
|---|---|---|---|---|---|---|---|
| | | | សរុបចំណូលឆ្នាំ២០១០ | | សរុបចំណូលឆ្នាំ២០១០ | | ភាគរយ |
| ១ | ដាក់ពាក្យ | ក្នុងស្រុក | ៨៤០ | ១៦.៨០០.០០០ | ៨០៦ | ១៦.១២០.០០០ | -៤,០% |
| | | ក្រៅស្រុក | ៣.១២៩ | ៦២.៥៨០.០០០ | ៣.៦៥៣ | ៧៣.០៦០.០០០ | ១៦,៧% |
| | | **សរុប** | **៣.៩៦៩** | **៧៩.៣៨០.០០០** | **៤.៤៥៩** | **៨៩.១៨០.០០០** | **១២,៣%** |
| ២ | ចុះបញ្ជីម៉ាក | ក្នុងស្រុក | ៦៥២ | ១១៧.៣៦០.០០០ | ៦៥៤ | ១១៧.៧២០.០០០ | ០,៣% |
| | | ក្រៅស្រុក | ២.៣៨៤ | ៤២៩.១២០.០០០ | ៣.០០៥ | ៥៤០.៩០០.០០០ | ២៦,០% |
| | | **សរុប** | **៣.០៣៦** | **៥៤៦.៤៨០.០០០** | **៣.៦៥៩** | **៦៥៨.៦២០.០០០** | **២០,៥%** |
| ៣ | ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ | | ១.៥១៤ | ៦០.៥៦០.០០០ | ១.៦៤១ | ៦៥.៦៤០.០០០ | ៨,៤% |
| ៤ | ការផ្ទេរសិទ្ធិម្ចាស់ម៉ាក | | ៣៤៦ | ១៣.៨៤០.០០០ | ៤៤៣ | ១៧.៧២០.០០០ | ២៨,០% |
| ៥ | ការប្តូរឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក | | ៤៤៥ | ១៧.៨០០.០០០ | ៤៦៧ | ១៨.៦៨០.០០០ | ៤,៩% |
| ៦ | ការកែតម្រូវនានា | | ២១ | ៨៤០.០០០ | ៤២ | ១.៦៨០.០០០ | ១០០% |
| ៧ | ការប្តូរឈ្មោះអាសយដ្ឋាន | | ៣៩១ | ១៥.៦៤០.០០០ | ៣៣៧ | ១៣.៤៨០.០០០ | -១៣,៨% |
| ៨ | ការលុបម៉ាក | | ៣២ | ៦.៤០០.០០០ | ១៧ | ៣.៤០០.០០០ | -៤៦,៩% |
| ៩ | ការចុះបញ្ជីម៉ាកសារឡើងវិញ | | ៩១២ | ១៨២.៤០០.០០០ | ៨៧៨ | ១៧៥.៦០០.០០០ | -៣,៧% |
| សរុប | | | | **៩២៣.៣៤០.០០០** | | **១.០៤៤.០០០.០០០** | **១៣,១%** |

**សន្និដ្ឋាន:**

ការរកចំណូលជូនរដ្ឋក្នុងឆ្នាំ២០១១នេះ បើបៀបធៀបទៅនឹងការរកចំណូលជូនរដ្ឋក្នុងឆ្នាំ ២០១០ បានចំនួន **៩២៣.៣៤០.០០០,០០៛** ឃើញថាមានការកើនឡើងចំនួន **១២០.៦៦០.០០០,០០៛** ស្មើនឹង **១៣,១%** ហើយបើប្រៀបធៀបទៅនឹងផែនការរកចំណូលឆ្នាំ២០១១ (**៩៦៥.៣៩៨.០០០,០០៛**) នាយកដ្ឋានបានអនុវត្តលើសផែនការ ៨,១%។

### ឃ-កិច្ចការជំនាញ

#### ឃ១-ការចុះបញ្ជីម៉ាក

##### ឃ១-១-ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក

នាយកដ្ឋានបានទទួលពាក្យស្នើសុំចុះបញ្ជីសរុបចំនួន **៤.៤៥៩** ម៉ាក ក្នុងនោះម៉ាក

-ក្នុងស្រុកចំនួន **៨០៦** ម៉ាក

-ក្រៅស្រុកចំនួន **៣.៦៥៣** ម៉ាក

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឆ្នាំ២០១១ សរុបបានចំនួន **៤.៤៥៩** ម៉ាក ហើយបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា ឆ្នាំ ២០១០ ដែលទទួលបានចំនួន **៣.៩៦៩** ម៉ាក ឃើញថាមានការកើនឡើងចំនួន **៤៩០ ម៉ាក** ស្មើនឹង **១២,៣%** ។

### ឃ១-២-ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មី

នាយកដ្ឋានបានឯកភាពចុះបញ្ជីជូនអតិថិជនសរុបចំនួន **៣.៦៥៩** ម៉ាក ក្នុងនោះម៉ាក

-ក្នុងស្រុកចំនួន **៦៥៤** ម៉ាក

-ក្រៅស្រុកចំនួន **៣.០០៥** ម៉ាក

ក្នុងឆ្នាំ ២០១១ នាយកដ្ឋានបានឯកភាពចុះបញ្ជីម៉ាក បានចំនួន **៣.៦៥៩** ម៉ាក ហើយបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ ២០១០ ចុះបញ្ជីបានចំនួន **៣.០៣៦ ម៉ាក** ឃើញថាមានការកើនឡើងចំនួន **៦២៣** ម៉ាក ស្មើនឹង **២០,៥%** ។

### ឃ១-៣-កិច្ចការក្រោយចុះបញ្ជីម៉ាក

-ការដាក់ពាក្យ និងការបញ្ជាក់ពាក្យប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក(Affidavit) **១.៦៤១**

-ការកត់ត្រា កាផ្ទេរសិទ្ធិម៉ាក (Assignment) **៤៤៣**

-ការកត់ត្រា ការប្តូរឈ្មោះ ឬបញ្ចូលគ្នានៃម្ចាស់ម៉ាក (Name Change and Merger) **៤៦៧**

-ការកែតំរូវនានា(Amendment) **៤២**

-ប្តូរអាស័យដ្ឋាន (Change Address) **៣៣៧**

-ការលុបម៉ាកចេញពីបញ្ជី **១៧**

-ចុះបញ្ជីសាឡើងវិញ (Renewal) **៨៧៨**

## ខ-ការងារបោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ

ក្នុងឆ្នាំ២០១១ នាយកដ្ឋានបានបោះពុម្ពព្រឹត្តិប័ត្រផ្លូវការ (Offocial Gazette) បានសរុបចំនួន ១២លេខ គឺចាប់ពីលេខ ១៣១ ដល់ ១៤២ ដើម្បីសំរាប់ផ្សព្វផ្សាយជាសាធារណៈ។

## ច-ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និងការលុបម៉ាកចេញពីបញ្ជី

### ច១-១-ការងារទទួលពាក្យ

នៅក្នុងឆ្នាំ ២០១១ នេះនាយកដ្ឋានបាន

-ទទួលពាក្យបណ្តឹងសរុបចំនួន **៤២** ករណី ស្មើ **៥៧** ម៉ាកក្នុងនោះរួមមានពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពាន (សូមមើលតារាង ក) មានចំនួន **២៦** ករណី ស្មើ **៣២** ម៉ាក និងពាក្យស្នើសុំលុបម៉ាក (សូមមើលតារាង ខ) មានចំនួន **១៦** ករណី ស្មើ **២៥** ម៉ាក ។

-ទទួលពាក្យបណ្តឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចំនួន ០៣ម៉ាក

### ច១-២-ការដោះស្រាយការរំលោភបំពាន

ក្នុងឆ្នាំ ២០១១ នេះនាយកដ្ឋានបាន

-ពិនិត្យពាក្យបណ្ដឹងចំនួន **២៩** ករណី (ក្នុងឆ្នាំ ២០១១ទទួលបាន ចំនួន **២៦** ករណី និងសល់ពីឆ្នាំ ២០១០ **៣** ករណី) និងបានដោះស្រាយការរំលោភបំពានបានចំនួន **២០** ករណី ក្នុងនោះរួមមានការធ្វើការសំរបសំរួលដោយមានកំណត់ហេតុចំនួន **៨** ករណី ធ្វើលិខិតបញ្ជាក់ពីភាពស្រដៀង និងសុពលភាពប្រើប្រាស់ម៉ាកមានចំនួន **១០** ករណី កែតម្រូវចំនួន **១** ករណី បដិសេធពាក្យបណ្ដឹងចំនួន **១** ករណី ហើយនៅសល់ **៩** ករណីទៀត ការិយាល័យកំពុងបន្តពិនិត្យ និងដោះស្រាយ ។

| ស្ថិតិការរំលោភបំពានកម្មសិទ្ធបញ្ញាក្នុងឆ្នាំ ២០១១ | | | | |
|---|---|---|---|---|
| | | ការដោះស្រាយ | | |
| **ឆ្នាំ** | **ការទទួលពាក្យបណ្ដឹង** | ការដក និង បដិសេធ ពាក្យបណ្ដឹង | ការបញ្ជាក់ផ្សេងៗ ចេញលិខិតព្រមាន កែតម្រូវ សំរបសំរួល និងបញ្ជាក់ភាពស្រដៀង | **នៅសល់** |
| ២០១០ | | | | ៣ |
| ២០១១ | ២៦ | ១ | ១៩ | |
| សរុប | ២៩ | ១ | ១៩ | ៩ |

-ដោះស្រាយការរំលោភបំពានម៉ាកសម្គាល់ភូមិសាស្រ្តទំនិញបានចំនួន ០២ម៉ាក

## តារាងសង្ខេប ការងារដោះស្រាយវិវាទរំលោភបំពាន ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ

| ល.រ | ភាគីដើមចោទ/ ភាគីសំណូមពរ | ខ្លឹមសារនៃពាក្យបណ្ដឹង | កាលបរិច្ឆេទ | ភាគីចុងចោទ/ ស្ថាប័នពាក់ព័ន្ធ | លទ្ធផលនៃការដោះស្រាយ |
|---|---|---|---|---|---|
| ០១ | សមាគមលើកកម្ពស់ម្រេចកំពត | ការក្លែងបន្លំឈ្មោះម្រេចកំពតដែលជាទំនិញសម្គាល់ភូមិសាស្រ្ត | ១១ -០២-២០១១ | **លោកស្រី គឹម លី** ម្ចាស់ហាងនៅផ្សារក្ដាម ខេត្រកែប (**មិនមែនជាសមាជិកសមាគម**) | មិនទាន់ដោះស្រាយ |

| | | | | | |
|---|---|---|---|---|---|
| ០២ | សមាគមលើកកម្ពស់ម្រេចកំពត | ការក្លែងបន្លំឈ្មោះម្រេចកំពតដែលជាទំនិញសម្គាល់ភូមិសាស្ត្រ | ២១ - ០៦- ២០១១ | **លោក លី ពិសី** នាយកប្រតិបត្តិក្រុមហ៊ុន **លី ពិសី** (**មិនមែនជាសមាជិកសមាគ**) | **លោក លី ពិសី**បានសន្យាថា : ១-ឈប់ប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"ម្រេចកំពត" ២-ប្តូរដាក់ម៉ាកផ្សេងជំនួសវិញ |
| ០៣ | **លោក ហៀង យៀង** នាយកប្រតិបត្តិក្រុមហ៊ុន **ហៀង យៀង** (**ជាសមាជិកសមាគម** ) | សំណើរសុំអន្តរាគមន៍ពីនាយកដ្ឋានកម្មសិទ្ធិបញ្ញាលើការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រ "ម្រេចកំពត" កុំឲ្យសមាគមដកសមាជិកភាពរបស់លោកចេញពីសមាគម | ០៥ - ០៧- ២០១១ | នាយកដ្ឋានកម្មសិទ្ធិបញ្ញា | **លោក ហៀង យៀង** បានលើកឡើងថា : ១-លោកគ្មានបទពិសោធន៍ និងធ្វេសប្រហេសក្នុងការកត់ត្រាបញ្ជីគណៈនេយ្យផលិតផលនូវរាល់ការលក់ចេញ ។ ២-លោកបានសំណូមពរឲ្យសមាគមអនុគ្រោះនិងធ្វើការពិចារណាឡើងវិញលើការដកសមាជិកភាពរបស់លោកចេញពីសមាគម និងផ្តល់ឱកាសឲ្យលោកធ្វើការកែកំហុសសាជាថ្មី ។ |

## ច១-៣-ការលុបម៉ាកចេញពីបញ្ជី

ក្នុងឆ្នាំ ២០១១ នេះ នាយកដ្ឋានបានពិនិត្យពាក្យស្នើសុំលុបម៉ាកចំនួន **៣៦** ករណី ស្មើ **៥២** ម៉ាក (ក្នុងឆ្នាំ ២០១១ ទទួលបាន **១៦** ករណី ស្មើ **២៥** ម៉ាក និងនៅសល់ពីឆ្នាំ ២០១០ ចំនួន **២០** ករណី ស្មើ **២៧** ម៉ាក) និងបានដោះស្រាយចំនួន **១៦** ករណី ស្មើ **២៥** ម៉ាក ក្នុងនោះរួមមានការលុបម៉ាកចេញពីបញ្ជីចំនួន **១៣** ករណី ស្មើ **១៧** ម៉ាក កែតម្រូវម៉ាកសារជាថ្មីចំនួន **១** ករណី ស្មើ **១** ម៉ាក និងនាយកដ្ឋាន បានចេញលិខិតរក្សាសុពលភាព **២** ករណី ស្មើ **៤** ម៉ាក ហើយនៅសល់ **២០** ករណី ស្មើ **៣០** ម៉ាក ការិយាល័យកំពុងបន្តពិនិត្យ និងដោះស្រាយ ។

| ស្ថិតិនៃការលុបម៉ាកក្នុងឆ្នាំ ២០១១ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | | ការដោះស្រាយ | | | | | | នៅសល់ | |
| | | | ការបដិសេធន៍ និងដកពាក្យបណ្តឹង | | លុប | | រក្សាសុពលភាព និង កែតម្រូវ | | | |
| | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក |
| ២០១០ | | | | | | | | | **២០** | **២៧** |
| ២០១១ | ១៦ | ២៥[1] | | | ១៣ | ១៧ | ៣ | ៥ | | |
| សរុប | ៣៦ | ៥២[2] | | | ១៣ | ១៧[3] | ៣ | ៥[4] | ២០ | ៣០ |

*១/ ក្នុង២៥ម៉ាក មាននាមករណ៍ក្រុមហ៊ុន ១ ។*

*២/ ក្នុង៥២ម៉ាក មាននាមករណ៍ក្រុមហ៊ុន ១ ។*

*៣/ ក្នុងចំណោម ១៧ម៉ាកនេះ មានពាក្យស្នើសុំលុបម៉ាកខ្លួនឯងចំនួន ៤ម៉ាក និងពាក្យបណ្តឹងលុបម៉ាកចំនួន ១៣ម៉ាក ។*

*៤/ ក្នុងចំណោម ៤ម៉ាកនេះ មានរក្សាសុពលភាព ៤ម៉ាក និងកែតម្រូវ ១ម៉ាក ។*

### ច១-៤-ការប្រៀបធៀប

បើធ្វើការប្រៀបធៀបការទទួលពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាក្នុងឆ្នាំ២០១១នេះ នឹងឆ្នាំ ២០១០ គឺថយចុះចំនួន **២** ករណី ឬថយចុះ **៧,១៤%** ហើយការទទួលពាក្យ ស្នើសុំលុបម៉ាកចេញពីបញ្ជីមានការថយចុះចំនួន **១៤** ករណី ឬថយចុះ **៩៥,១៦%**។ ចំណែកលទ្ធផល នៃការដោះស្រាយការរំលោភបំពានក្នុងឆ្នាំ ២០១១ មានចំនួន **២០** ករណី បើធៀនឹងឆ្នាំ ២០១០ គឺមានការថយចុះ **១២** ករណី ឬថយចុះ **៣៧,៥%**។ ដោយឡែកការលុបម៉ាកចេញពីបញ្ជីក្នុងឆ្នាំ ២០១១ នេះមានចំនួន **១៧** ម៉ាក បើធៀនឹង ឆ្នាំ ២០១០ គឺមានការថយចុះចំនួន **១៥** ម៉ាក ឬថយចុះ **៤៧%**។

### ក្រាហ្វិចប្រៀបធៀប ឆ្នាំ ២០១១ ធៀបនៅនឹងឆ្នាំ ២០១០ និង ២០០៩



ទោះបីសកម្មភាពរំលោភបំពានម៉ាកនៅក្នុងឆ្នាំ២០១១ មានការថយចុះក៏ដោយក៏មិនមែនជាសូចនាករមួយ ឆ្លុះបញ្ចាំងពីសកម្មភាពរំលោភ បំពានកម្មសិទ្ធិបញ្ញា នៅក្នុងប្រទេសកម្ពុជាទាំងមូលនោះឡើយ ប៉ុន្តែវាជាសូចនាករមួយជ្រុងបង្ហាញ ឲ្យឃើញថា សកម្មភាពរំលោភបំពាននៃម៉ាកមានការថយចុះ ហើយសកម្មភាពពាណិជ្ជកម្មមានភាព ល្អតលាស់កាន់តែប្រសើរឡើង ទន្ទឹមនឹងនេះការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជ្រាបចូលក្នុងស្រទាប់មហាជនកាន់តែប្រសើរឡើង ហើយម្ចាស់កម្មសិទ្ធិបញ្ញាបានចាប់អារម្មណ៍ ដល់ការការពារផលប្រយោជន៍ ដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ដោយផ្តួចផ្តើមចាត់វិធានការចំពោះការ រំលោភបំពានទាំងនោះ ទៅតាមស្ថាប័នអនុវត្តកម្មសិទ្ធិបញ្ញាដែលមានស្រាប់។

### សន្និដ្ឋាន

សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាគួរឲ្យគត់សម្គាល់នៅឡើយ ហើយការអនុវត្តន៍កម្មសិទ្ធិបញ្ញាមិនអាចប្រព្រឹត្តទៅដោយរលូនបានទេ ប្រសិនបើម្ចាស់កម្មសិទ្ធិបញ្ញា នៅតែប្រងើយកន្តើយចំពោះការរំលោភបំពានទាំងនោះ គួរតែម្ចាស់កម្មសិទ្ធិបញ្ញាសហការជាមួយសមត្ថកិច្ច ដើម្បីធ្វើការទប់ស្កាត់ការរំលោភបំពានឲ្យកាន់តែមានប្រសិទ្ធិភាព ដើម្បីលើកស្ទួយការបង្កើនសម្បត្តិកម្មសិទ្ធបញ្ញា ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## II- ទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ ២០១២

នាយកដ្ឋានមានទិសដៅអនុវត្តការងារ ដូចខាងក្រោម:

- បន្តរៀបចំសេចក្តីប្រកាសស្តីពី នីតិវិធីចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាក។
- សហការរៀបចំកម្មវិធីសិក្សាសំរាប់ថ្នាក់មហាវិទ្យាល័យ និងមហាជន។
- រៀបចំគម្រោង IP Academy ដើម្បីស្នើជំនួយពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក
- អនុវត្តគម្រោង Pillar 1 ។

- នៅក្រោមគម្រោង Enhanced Integrated Framework សេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ពាណិជ្ជកម្ម នឹងរំពឹងថានឹងត្រូវអនុម័តចប់សព្វគ្រប់នៅឆ្នាំ ២០១៣ ។

-រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់ កម្មសិទ្ធិបញ្ញា និង អនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ ។

-រៀបចំអនុក្រឹត្យស្តីពី «វិធានការណ៍តាមព្រំដែន»។

- រៀបចំអនុក្រឹត្យស្តីពី «ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ( Sub-Decree on Enforcement of IPRs)»។

-បន្តសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីបញ្ចប់ឲ្យបានឆាប់នូវសេចក្តីព្រាងច្បាប់ ស្តីពី"ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ" និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី តាមពេល វេលាសមស្របណាមួយ។

-សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិ នៃការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ (MADRID SYSTEM)។

-ត្រៀមរៀបចំបង្កើយនីតិវិធីពាក់ព័ន្ធនានា ដើម្បីត្រៀមទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក សមូហភាព (Collective Mark) នាពេលដ៏ខ្លីខាងមុខនេះ។

-ត្រៀមរៀបចំធ្វើកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំង ដើម្បីការអភិវឌ្ឍន៍(**Agence** Française de Développement, AFD) និងអង្គការស្បៀងអាហារ និង កសិកម្ម ពិភពលោក(**FAO, Food and Agriculture of the United Nation**) ដើម្បីអនុវត្តគម្រោងថ្នាក់តំបន់ ស្តីពីការសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសមាជិកចំនួន ០៤ ប្រទេស គឺ កម្ពុជា វៀតណាម ឡាវ និង ថៃឡង់ដ៍ ក្នុងគោលបំណងផ្លាស់ប្តូរចំណេះដឹង រវាងប្រទេស ជាសមាជិក ក្នុងវិស័យសម្គាល់ភូមិសាស្ត្រទំនិញ ។

-បន្តសហការជាមួយអាជ្ញាធរដែនដី និង ក្រសួងជំនាញដែលមានការពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និង ការកំណត់តំបន់ភូមិសាស្ត្រផលិតផលដែលមានសក្តានុពល ដើម្បីឈានដល់ការចុះបញ្ជីការពារ ជាផលិតផលសម្គាល់ភូមិសាស្ត្រ នាថ្ងៃអនាគត ។

- បន្តសហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ **(DICO)** និងសម្រាប់គម្រោងស្នើសុំហិរញ្ញប្បទាន ដើម្បីអនុវត្តផលិតផលពីរមុខ "ផលិតផលធូរេនកំពត និង ស្ករត្នោតភ្នំស្រុក" ។

-ជំរុញដោះស្រាយរាល់វិវាទទាក់ទិននឹងការរំលោភបំពាន និងការលុបម៉ាក ដែលនៅសេសសល់។

-បន្តបង្កើនកិច្ចសហការឲ្យកាន់តែជិតស្និទ្ធ និងមានលក្ខណៈកាន់តែប្រសើរឡើងថែមទៀតជាមួយអង្គភាពពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចនានា ដើម្បីកាត់បន្ថយការ រំលោភបំពានកម្មសិទ្ធិបញ្ញាឲ្យបានជាអតិបរិមា។

-បន្តធ្វើទំនើបឡើងនូវប្រព័ន្ធគ្រប់គ្រង និងចុះបញ្ជីពាណិជ្ជសញ្ញា ដោយៈបន្តបញ្ចូនទិន្នន័យម៉ាកដែលបានចុះបញ្ជីហើយទៅក្នុង Computer Database តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (IPAS)និងធ្វើឲ្យប្រសើរឡើងពី IPAS ទៅ IPAS JAVA ។

-ពង្រឹងដំណើរការត្រួតពិនិត្យម៉ាកដោយស្វ័យប្រវត្តិតាមរយៈ computer ចំពោះម៉ាកជារូបភាព

-បន្តរៀបចំកែលំអរប្រព័ន្ធចុះបញ្ជីម៉ាក តាមរយៈស័យប្រវត្តិកម្ម (Computerization of Trademark Registration) អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ និងសុក្រឹត្យ។

-បន្តជូនដំណឹងដល់អតិថិជន ឲ្យមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយៈពេល ១០ ឆ្នាំរួច។

-រៀបចំឲ្យមានមជ្ឈមណ្ឌលពត៌មានកម្មសិទ្ធិបញ្ញាមួយ សំរាប់បំរើដល់អតិថិជនដែលមានបំណងចង់ស្វែងយល់ពីកម្មសិទ្ធិបញ្ញា និយាយរួម និង និយាយដោយឡែកពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬឯកសារនានាដែលទាក់ទងនឹងការចុះបញ្ជីម៉ាក និងវិវាទនានានៅកម្ពុជា។

-រៀបចំយន្តការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់មហាជន និងអាជីវករ អំពីច្បាប់ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជាពិសេសច្បាប់ស្តីពីម៉ាក ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់។

-រៀបចំបោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រផ្លូវការឲ្យបានចំនួន ១២ លេខក្នុងមួយឆ្នាំ ព្រមទាំងបញ្ចូល ឯកសារទៅក្នុងCDដើម្បីចែកជូនអតិថិជនក្នុង និងក្រៅប្រទេសដែលបានចុះបញ្ជីការម៉ាក របស់ខ្លួននៅកម្ពុជា និងខិតខំធ្វើព្រឹត្តិប័ត្រផ្លូវការជា CDs ។

-ពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ដោយបង្កើតកិច្ចសហការឲ្យបានកាន់តែជិតស្និទ្ធថែមទៀតជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីកាត់បន្ថយការរំលោភកម្មសិទ្ធិបញ្ញាឲ្យបានជាអតិបរមា។

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក និង ការទទួលស្គាល់ភ្នាក់ងារ។

-ពង្រឹងសមត្ថភាពមន្ត្រីនៅក្នុងនាយកដ្ឋាន ដើម្បីអាចធ្វើជាគ្រូបង្ហាត់វិស័យកម្មសិទ្ធិបញ្ញា។

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយទស្សនាទានផលិតផលសម្គាល់ភូមិសាស្រ្ត ច្បាប់ស្តីពី **"ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ"** នៅពេលដែលច្បាប់នេះ ត្រូវបានអនុម័តដោយរដ្ឋសភារួចហើយ ក្នុងគោលដៅជម្រុញការចុះបញ្ជីផលិតផលសម្គាល់ភូមិសាស្រ្តទាំងក្នុង និង ក្រៅប្រទេស ។

-ជម្រុញការសិក្សាបន្ថែម និង ស្វែងរកដៃគូរលើផលិតផលដែលបានកំណត់អត្តសញ្ញាណរួចហើយ ដូចជា សូត្រភ្នំស្រុក ធូរេនកំពត អង្ករនាងអំក្រចេះ អង្គបាត់ដំបង ប្រហុកសៀមរាប ក្រូចពោធិសាត់ ទឹកឃ្មុំមណ្ឌលគីរីជាដើម ដើម្បីឈានទៅរកការចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ។

-បន្តរៀបចំនីតិវិធីពាក់ព័ន្ធនានា ដើម្បីត្រៀមទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព ។

-បន្តស្វែងរកដៃគូរអភិវឌ្ឍន៍ដើម្បីជួយគាំទ្រដល់ គម្រោងការពារម៉ាកសម្គាល់ ភូមិសាស្រ្តទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ភ្នំពេញ,ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១១

**អនុប្រធាននាយកដ្ឋាន**

ស៊ឹម សុខខេង